# សេចក្តីថ្លែងការណ៍រួម

## ស្តីពី

# ការហាមឃាត់ពីសំណាក់អាជ្ញាធរចំពោះភាពសកម្មរបស់ប្រជាពលរដ្ឋ មូលដ្ឋានប៉ះពាល់យ៉ាងខ្លាំងដល់ការអភិរក្សព្រៃឡង់

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០

យើងខ្ញុំ មានរាយនាមដូចខាងក្រោម សូមសម្តែងការសោកស្តាយ និងហួសចិត្តជាខ្លាំង ចំពោះការរឹតត្បិតរបស់អាជ្ញាធរក្នុងការហាមឃាត់សមាជិកសហគមន៍ ព្រះសង្ឃ និង សកម្មជនបរិស្ថានរាប់រយនាក់ ដែលធ្វើដំណើរចូលទៅកាន់តំបន់ការពារព្រៃឡង់ កាលពី ចុងសប្តាហ៍មុននេះ។ ការប្រើប្រាស់មន្ត្រីឧទ្យានុរក្សប្រដាប់ដោយកាំភ្លើងរបស់ក្រសួងបរិស្ថាន ដើម្បីរារាំងសមាជិកបណ្តាញសហគមន៍ព្រៃឡង់ ពីការប្រារព្ធពិធីបុណ្យបំបួសដើមឈើ ប្រចាំឆ្នាំនៅក្នុងព្រៃ គឺជាការរឹតត្បិតមិនសមហេតុផលទៅលើសេរីភាពនៃការដើរហើរ និង បង្អាក់ការខិតខំប្រឹងប្រែងអភិរក្សព្រៃឈើ។

បណ្តាញសហគមន៍ព្រៃឡង់ បានបង្ហាញសាធារណជនឱ្យឃើញថា ជាអ្នកឃ្លាំមើល និងតស៊ូមតិដោយមានប្រសិទ្ធភាព និងក្លាហានជាងគេ អស់រយៈពេលជាង២០ឆ្នាំចុងក្រោយ នេះ។ បណ្តាញសហគមន៍នេះមានចម្រុះនូវសមាជិកសហគមន៍ជាច្រើនដែលជីវិត និងជីវភាព រស់នៅរបស់អ្នកទាំងនេះ ផ្សារភ្ជាប់គ្នាយ៉ាងខ្លាំងជាមួយព្រៃឈើ ហើយអ្នកទាំងនេះត្រូវការ ចូលទៅកាន់តំបន់នេះដើម្បីការពារព្រៃឈើដោយគ្មានការរឹតត្បិត។ ទោះបីជាក្រុមសហគមន៍ បានជូនដំណឹងទៅអាជ្ញាធរពីបំណងក្នុងការប្រារព្ធពិធីបុណ្យប្រចាំឆ្នាំនៅក្នុងព្រៃនេះក៏ដោយ ក៏មន្ត្រីក្រសួងបរិស្ថានបានហាមឃាត់សមាជិកសហគមន៍ទាំងនេះមិនឱ្យចូលទៅកាន់ព្រៃឡង់ ដោយមិនបានផ្តល់អំណះអំណាងផ្លូវច្បាប់សមហេតុផលឡើយ។

លោក ហឿន សុភាព តំណាងបណ្តាញសហគមន៍ព្រៃឡង់នៅខេត្តកំពង់ធំ បានមាន ប្រសាសន៍ថា៖ "កាលពីមុន យើងអាចចូលទៅព្រៃឡង់ដោយសេរីដើម្បីធ្វើសកម្មភាពរបស់ យើងក្នុងការការពារព្រៃនេះ"។ លោកបានបន្តថា៖ "ប៉ុន្តែថ្មីៗនេះ យើងមានការលំបាកកាន់តែ ខ្លាំងឡើងៗ ហើយក្រសួងរឹតត្បិតសកម្មភាពរបស់ពួកយើងច្រើនឡើងៗផងដែរ"។

បន្ទាប់ពីបានបដិសេធមិនឱ្យសមាជិកសហគមន៍ចូលព្រៃ ក្រសួងបរិស្ថានបានសរសេរបង្ហោះសារនៅលើបណ្ដាញទំនាក់ទំនងហ្វេសប៊ុកថា មាត្រា១១នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ ហាមឃាត់មិនឱ្យអ្នកណាចេញចូលតំបន់ការពារធម្មជាតិដោយគ្មានការអនុញ្ញាតទេ។ មាត្រា១១នេះ សំដៅលើតំបន់ដែលបានកំណត់និងបែងចែករួច ហើយមានតែតំបន់ស្នូលប៉ុណ្ណោះដែលជាតំបន់ការពារខ្លាំងជាងគេក្នុងចំណោមតំបន់ទាំងបួន ដែលតម្រូវឱ្យមានការអនុញ្ញាតពីក្រសួងមុនពេលចូលទៅកាន់តំបន់ការពារធម្មជាតិ។ ប៉ុន្តែច្រើនឆ្នាំបន្ទាប់ពីអនុម័តច្បាប់នេះក្នុងឆ្នាំ២០១៦ មិនទាន់មានការកំណត់ និងបែងចែកតំបន់ព្រៃឡង់នៅឡើយទេ ទោះបីជាការកំណត់និងបែងចែកតំបន់ការពារនេះត្រូវបានឡើងលើកទឹកចិត្តដោយក្រុមអ្នកអភិរក្សបរិស្ថានក៏ដោយ ដោយសារវាជាកិច្ចការពារបន្ថែមប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ។

សាររបស់ក្រសួងក៏សំដៅលើ ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាកង្វល់លើកឡើងដោយសហគមន៍និងអង្គការសង្គមស៊ីវិលជាង១០០ស្ថាប័ន កាលពីដើមខែនេះ នៅក្នុងសេចក្ដីថ្លែងការណ៍មួយដើម្បីជំរុញឱ្យអាជ្ញាធរនិរាករណ៍ច្បាប់នេះទាំងស្រុងដោយសារតែភាពមិនច្បាស់លាស់ និងជាឧបករណ៍ប្រើសម្រាប់រំលោភបំពាន។ ទោះបីជាមានការធានាពីក្រសួងមហាផ្ទៃថា ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនឹងមិនត្រូវបានប្រើសម្រាប់រឹតត្បិតសកម្មភាពរបស់ក្រុមសហគមន៍មូលដ្ឋានក៏ដោយ ក៏ក្រសួងបរិស្ថានបានប្រើប្រាស់ច្បាប់នេះជាហេតុផល ដើម្បីរារាំងសកម្មភាពអភិរក្សព្រៃឈើស្របច្បាប់របស់បណ្ដាញសហគមន៍ព្រៃឡង់។ ការប្រើប្រាស់ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីហាមឃាត់សមាជិកសហគមន៍ពីការធ្វើពិធីបុណ្យបំបួសដើមឈើនៅតំបន់ព្រៃការពារ បង្ហាញជាថ្មីម្ដងទៀតពីផលប៉ះពាល់នៃច្បាប់នេះក្នុងទម្រង់បច្ចុប្បន្ន។

លោក អំ សំអាត នាយករងកម្មវិធីឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ បានមានប្រសាសន៍ថា៖ "ការប្រើប្រាស់ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំពោះបណ្ដាញសហគមន៍ព្រៃឡង់ គឺជាការរឹតត្បិតយ៉ាងខ្លាំង និងមិនសមស្របតាមច្បាប់"។ លោកបានបន្ថែមថា៖ "បណ្ដាញសហគមន៍នេះគួរត្រូវបានអនុញ្ញាត ដើម្បីធ្វើការសកម្មភាពអភិរក្សរបស់ខ្លួនដោយគ្មានការធ្វើទុក្ខបុកម្នេញនិងគំរាមកំហែង"។

ចុងក្រោយនេះ ក្រសួងបានចោទប្រកាន់បណ្ដាញសហគមន៍ព្រៃឡង់ថាបានព្យាយាមប្រើប្រាស់ "ទិន្នន័យដែលមិនមានមូលដ្ឋានវិទ្យាសាស្ត្រត្រឹមត្រូវ" និង "ចងក្រងបំប៉ោងរបាយការណ៍"។ បណ្ដាញសហគមន៍ព្រៃឡង់បានធ្វើការស្រាវជ្រាវជាទៀងទាត់

ផ្អែកលើភស្តុតាងបង្ហាញពីការកាប់បំផ្លាញព្រៃឈើនៅតំបន់ការពារព្រៃឡង់ ជាអ្វីដែលក្រសួងបរិស្ថានគួរតែអបអរសាទរ និងយកទៅប្រើប្រាស់ ហើយមិនគួរត្រូវបានរិះគន់ឬបដិសេធចោលនោះទេ។

យើងខ្ញុំយកចិត្តទុកដាក់ជាខ្លាំងអំពីព្រៃឈើប្រទេសកម្ពុជា ដែលត្រូវបានបាត់បង់ជាបន្តបន្ទាប់នៅប៉ុន្មានទសវត្សចុងក្រោយនេះ។ យើងខ្ញុំបានដឹងពីបទពិសោធន៍ថា ការលះបង់ និងការខិតខំប្រឹងប្រែងរបស់ក្រុមសហគមន៍មូលដ្ឋានដូចជា បណ្តាញសហគមន៍ព្រៃឡង់គឺមានប្រសិទ្ធភាពជាងគេក្នុងការអភិរក្សតំបន់ព្រៃការពារ។ យើងខ្ញុំ សូមលើកទឹកចិត្តដល់ក្រសួងបរិស្ថាន សូមមេត្តាអនុវត្តសេចក្តីអំពាវនាវរបស់ក្រសួងចំពោះប្រជាពលរដ្ឋដើម្បីការពារធនធានធម្មជាតិ និងសូមឱ្យបញ្ឈប់សកម្មភាពនានា ក្នុងការបដិសេធការសិក្សាស្រាវជ្រាវ និងគំរាមកំហែងសមាជិកបណ្តាញសហគមន៍ព្រៃឡង់តទៅទៀត៕

**សេចក្តីថ្លែងការណ៍នេះ គាំទ្រដោយ៖**

១. សហគមន៍កៅពីរ (ភ្នំពេញ)
២. សហគមន៍ដីធ្លី១៩៧ (កោះកុង)
៣. សហគមន៍ដីធ្លី២៩៧ (កោះកុង)
៤. សហគមន៍អណ្តូងថ្ម (ព្រះសីហនុ)
៥. សហគមន៍អណ្តូងត្របែក (ស្វាយរៀង)
៦. សហគមន៍បាតខ្វះ (ព្រះសីហនុ)
៧. សហគមន៍បឹងឈូក (ភ្នំពេញ)
៨. សហគមន៍បឹងប្រាំ (បាត់ដំបង)
៩. សហគមន៍បុរីកីឡា (ភ្នំពេញ)
១០. សហគមន៍បុស្សស្នំ (បាត់ដំបង)
១១. សហគមន៍បុស្សស្មោរ (កំពង់ចាម)
១២. អង្គការព្រះពុទ្ធសាសនាសម្រាប់សន្តិភាព (BPO)
១៣. សហគមន៍សេ អ៊ី ប្រាំ (ព្រះសីហនុ)
១៤. អនាគតយុវជនកម្ពុជាអាស៊ាន (CamASEAN)
១៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
១៦. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
១៧. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)

១៨. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)
១៩. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ (CIWA)
២០. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC)
២១. សហភាពការងារកម្ពុជា (CLC)
២២. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
២៣. បណ្តាញយុវជនកម្ពុជា (CYN)
២៤. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
២៥. សហគមន៍ដីធ្លីចេកមាស (ស្វាយរៀង)
២៦. សហគមន៍ឆេកូ (ភ្នំពេញ)
២៧. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
២៨. សហគមន៍ដីធ្លីជីខលើ (កោះកុង)
២៩. សហគមន៍ជើងព្រៃ (កំពង់ចាម)
៣០. សហគមន៍ជាំក្រវៀន (កំពង់ចាម)
៣១. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
៣២. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៣៣. បណ្តាញសកម្មភាពដើម្បីសហគមន៍ (CNA)
៣៤. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
៣៥. សហគមន៍តំបែរ (ត្បូងឃ្មុំ)
៣៦. អង្គការសមធម៌កម្ពុជា (EC)
៣៧. សហគមន៍នេសាទអភិរក្សអភិវឌ្ឍន៍ធនធានជលផលកន្លែងភេ (កំពង់ឆ្នាំង)
៣៨. សហគមន៍អភិរក្សព្រៃឈើជីវៈចំរុះ (ស្វាយរៀង)
៣៩. សហគមន៍ព្រៃឈើ (រតនគិរី)
៤០. សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)
៤១. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
៤២. អង្គការទស្សនៈបៃតង
៤៣. សហគមន៍ហោងសំណំ (កំពង់ស្ពឺ)
៤៤. បណ្តាញព្រះសង្ឃឯករាជ្យដើម្បីយុត្តិធម៌សង្គម (IMNSJ)
៤៥. សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
៤៦. យុវជនជានជាតិដើមភាគតិចសម្រាប់ សហគមន៍ខេត្តរតនគិរី

៤៧. យុវជនជនជាតិដើមភាគតិច ឃុំប្រមេស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ
៤៨. សមាគមឥន្ទ្រទេវី
៤៩. សហាគមន៍កំពង់សាមគ្គី (កំពត)
៥០. សហាគមន៍ដីធ្លីគៀនទឹក (កោះកុង)
៥១. សហាគមន៍ឃ្លាំងទឹក ៧៨ (សៀមរាប)
៥២. សហាគមន៍ដីធ្លីកោះ ស្តេច (កោះកុង)
៥៣. សហាគមន៍ដីធ្លី (កំពត)
៥៤. សហាគមន៍ដីធ្លីឡពាង (កំពង់ឆ្នាំង)
៥៥. អង្គការការពារសិទ្ធិជន ជាតិដើមភាគតិច (MIRO)
៥៦. អង្គការម្លប់ព្រហ្មវិហារធម៌ (កោះកុង)
៥៧. សហាគមន៍ដីធ្លីមានជ័យ (ស្វាយរៀង)
៥៨. ចលនាមាតាធម្មជាតិ (MN)
៥៩. សហាគមន៍ការពារធនធានធម្មជាតិ (កំពង់ឆ្នាំង)
៦០. សហាគមន៍អមលាំង (កំពង់ស្ពឺ)
៦១. សហាគមន៍អូរឈើទាល (ព្រះសីហនុ)
៦២. សហាគមន៍អូរត្រជាក់ចិត្ត (ព្រះសីហនុ)
៦៣. សហាគមន៍អូរល្ហីព្រៃង (បាត់ដំបង)
៦៤. អង្គការស្ពានសន្តិភាព (PBO)
៦៥. សហាគមន៍ភ្នំបាត (ភ្នំពេញ)
៦៦. សហាគមន៍ភ្នំក្រោម (សៀមរាប)
៦៧. សហាគមន៍ភ្នំទទឹង (កំពត)
៦៨. សហាគមន៍ភូមិដីឆ្នាំង (កំពង់ស្ពឺ)
៦៩. សហាគមន៍ដីធ្លីភូមិផ្សារកណ្តាល (បន្ទាយមានជ័យ)
៧០. សហាគមន៍ភូមិអូរស្វាយ (បន្ទាយមានជ័យ)
៧១. សហាគមន៍ភូមិសមុទ្រក្រោម (រតនគិរី)
៧២. សហាគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
៧៣. សហាគមន៍ភូមិ២២ (ភ្នំពេញ)
៧៤. អង្គការពន្លកខ្មែរ (PKH)
៧៥. សហាគមន៍ប្រាសាក់ (បាត់ដំបង)

៧៦. សហគមន៍ដីធ្លីព្រែកខ្សាច់ (កោះកុង)
៧៧. សហគមន៍ព្រែក តាគង់ (ភ្នំពេញ)
៧៨. សហគមន៍ព្រែកតានូ (ភ្នំពេញ)
៧៩. សហគមន៍ព្រៃឈើអូរដំដែក (កំពង់ធំ)
៨០. សហគមន៍ព្រៃឈើពេជ្រ ចង្វារល្អឆើត (កំពង់ឆ្នាំង)
៨១. បណ្តាញសហគមន៍ព្រៃឡង់ (PLCN)
៨២. សហគមន៍ព្រែកនរិន្ទ (បាត់ដំបង)
៨៣. សហគមន៍ដីធ្លី ព្រៃពាយ (កំពត)
៨៤. សហគមន៍ផ្លូវរថភ្លើង (ភ្នំពេញ)
៨៥. សហគមន៍ដីធ្លីរំចេក (សៀមរាប)
៨៦. អង្គការគាំទ្របច្ចេកវិទ្យានៅជនបទក្នុងប្រទេសកម្ពុជា (RCTSO)
៨៧. សហគមន៍ដីធ្លីសាមគ្គីរមាសហែក (ស្វាយរៀង)
៨៨. សមាគមធាងត្នោត (STT)
៨៩. សហគមន៍ដីធ្លីស្តូន់ (សៀមរាប)
៩០. សហគមន៍នេសាទ សម្រស់កោះស្តេច (កោះកុង)
៩១. សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ
៩២. សហគមន៍ស្រែប្រាំង (កំពង់ចាម)
៩៣. សហគមន៍ដីធ្លីស្ទឹងបត់ (បន្ទាយមានជ័យ)
៩៤. សហគមន៍ដីធ្លីតានូន (កោះកុង)
៩៥. សហគមន៍ដីធ្លីតានី (សៀមរាប)
៩៦. គណៈកម្មាធិការនៃអង្គការមិនមែន រដ្ឋាភិបាលដើម្បីលុប បំបាត់រាល់ទម្រង់ រើសអើង លើស្ត្រីភេទ (NGO-CEDAW)
៩៧. សហគមន៍ដីធ្លីធ្មង់ (កោះកុង)
៩៨. សហគមន៍ទួលរ៉ាដា (ភ្នំពេញ)
៩៩. សហគមន៍ទួលសង្កែ (ភ្នំពេញ)
១០០. សហគមន៍ត្រពាំងសង្កែ (កំពត)
១០១. សហគមន៍ត្រពាំងជោរ (កំពង់ស្ពឺ)
១០២. សហគមន៍អភិរក្សអភិវឌ្ឍន៍ធនធានព្រៃឈើ (កំពង់ឆ្នាំង)
១០៣. Not1More (N1M)